AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

# ទំនាយជ័យឫក្ស

ពោលពីលក្ខណៈ ប្រកបទៅដោយឫកសំបូរជោគជ័យតាមវារៈថ្ងៃទៅតាមទម្រង់នាគពន្ធ ដូចតទៅ :

រូបភាពទំព័រ ២០៣



ថ្ងៃដែលជាជ័យឫក្សនេះ តាមបុរាណនិយមយកប្រើការខាងរិះរកទំនួលទិសមានជ័យជំនះក្នុងការលេងល្បែង ផ្សេងៗ បើមុននឹងចូលធ្វើពិធីហោមក្តី ធ្វើកិច្ចការមង្គលដូចជាកោរជុក បង្កក់ធ្នប់ក្តី ឬចូលដៃទៅក្នុងវង់ល្បែងភ្នាល់នានាក្តី គប្បីអង្គុយឱ្យត្រូវទិសក្បាលនាគឈមមុខទៅរកកន្ទុយនាគ កុំឱ្យច្រាស់ស្រលានាគឡើយ តាមទិសដូច្នេះ ។

១-ខ្ទីត និង រនោច ដូចគ្នា ថ្ងៃអាទិត្យ នាគបែរក្បាលទៅខាងទិសឧត្តរ កន្ទុយនាគទៅទិសអាគ្នេយ៍ គប្បីអង្គុយពីខាងជើងឈមមុខទៅកាន់អាគ្នេយ៍ ។

២-ថ្ងៃចន្ទ នាគបែរក្បាលទៅខាងទិសបស្ចឹម កន្ទុយនាគចាក់ទៅឦសាន គប្បីអង្គុយពីខាងទិសបស្ចឹម ឈមមុខទៅកាន់ទិសឦសាន ។

៣-ថ្ងៃអង្គារ នាគបែរក្បាលទៅខាងទិសបូព៌ កន្ទុយនាគចាក់ទៅខាងទិសនិរតី គប្បីអង្គុយពីខាងទិសបូព៌ ឈមមុខទៅកាន់ទិសនិរតី ។

៤-ថ្ងៃពុធ នាគបែរក្បាលទៅខាងទិសនិរតី កន្ទុយចាក់ទៅខាងទិសពាយ័ព្យ គប្បីអង្គុយពីខាងទិសនិរតី ឈមមុខទៅកាន់ទិសពាយ័ព្យ ។

៥-ថ្ងៃព្រហស្បតិ៍ នាគបែរក្បាលទៅខាងទិសឦសាន កន្ទុយចាក់ទៅខាងទិសអាគ្នេយ៍ អង្គុយពីឦសាន ឈមមុខទៅកាន់ខាងទិសអាគ្នេយ៍ ។

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

៦-ថ្ងៃសុក្រ នាគបែរក្បាលទៅខាងទិសអាគ្នេយ៍ កន្ទុយចាក់ទៅខាងទិសបស្ចឹម គប្បីអង្គុយពីខាងទិសអាគ្នេយ៍ ឈមមុខត្រង់ទៅកាន់បស្ចឹមទិស ។

៧-ថ្ងៃសៅរ៍ នាគបែរក្បាលទៅខាងទិសទក្សិណ ឈមមុខត្រង់ទៅទិសពាយ័ព្យអង្គុយពីខាងទិសទក្សិណ ឈមមុខត្រង់ទៅចំទិសពាយ័ព្យ ។

កាលបានប្រតិបត្តិត្រូវទំនងនេះមែន ពិតជាមានជោគជ័យគ្រប់ទេសៈកាលៈ

**ចប់**